Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

Brot für die Welt

DCA actalliance

API BUILDING CAPACITY FOR CHANGE

# ការវិភាគសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

## សេចក្តីព្រាងថ្ងៃទី ២០-២១ ខែវិច្ឆិកាឆ្នាំ ២០១៩

### វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ

### ២៨ ធ្នូ ២០១៩




ខ្លឹមសារនៃសារបោះពុម្ពផ្សាយ
មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ SDC,
BfDW និង DCA ឡើយ។

## សេចក្តីសង្ខេបរួម

សិទ្ធិទទួលបានព័ត៌មានស្ថាប័នសាធារណៈ (ក៏ត្រូវបានគេស្គាល់ផងដែរថាជា" សេរីភាពព័ត៌មាន" ឬ" សិទ្ធិដឹង") ដែលច្បាប់អន្តរជាតិបានទទួលស្គាល់ជាសិទ្ធិមូលដ្ឋានរបស់មនុស្ស។ ទោះបីគេមិនបានដាក់ថា " សិទ្ធិទទួលព័ត៌មាន" យ៉ាងជាក់លាក់នៅក្នុងដំណាក់កាលដំបូងនៃសន្ធិសញ្ញាសិទ្ធិមនុស្សនិងឯកសារពាក់ព័ន្ធរបស់វាក៏ដោយ ប៉ុន្តែឥឡូវនេះសិទ្ធិនេះត្រូវបានទទួលស្គាល់ជាទូទៅថាជាផ្នែកមួយនៃសិទ្ធិជាមូលដ្ឋាននៃសេរីភាពក្នុងការបញ្ចេញមតិដែលរួមទាំងសិទ្ធិក្នុងការស្វែងរក ទទួលបាននិងផ្សព្វផ្សាយព័ត៌មាន។ ឥឡូវនេះមានប្រទេសជាង ១២០ ជុំវិញពិភពលោកបានអនុម័តច្បាប់ ឬគោលនយោបាយសិទ្ធិទទួលព័ត៌មាន (អាចសរសេរកាត់ជាA2I)ទៅជាច្បាប់ឬគោលនយោបាយរបស់ប្រទេសពួកគេ។

នៅប្រទេសកម្ពុជា សិក្ខាសាលា កិច្ចប្រជុំពិគ្រោះយោបល់និងសន្និសីទ ស្តីពីសិទ្ធិទទួលព័ត៌មានបានរៀបចំអស់រយៈពេលជាងមួយទសវត្សរ៍មកហើយ ដែលក្នុងនោះមានការចូលរួមពីមន្ត្រីរដ្ឋាភិបាល សមាជិកអង្គការសង្គមស៊ីវិល និងអ្នកជំនាញច្បាប់។ សេចក្តីព្រាងឯកសារក្របខណ្ឌគោលនយោបាយមួយស្តីពីសិទ្ធិទទួលបានព័ត៌មាន ត្រូវបានគេបញ្ចប់នៅឆ្នាំ ២០០៧។ នៅឆ្នាំ ២០១៥ ក្រុមការងារបច្ចេកទេសដែលរួមមានមន្ត្រីក្រសួងព័ត៌មាន មន្ត្រីយូណេស្កូ តំណាងអង្គការសង្គមស៊ីវិល និងអ្នកជំនាញផ្នែកច្បាប់ ត្រូវបានគេបង្កើតឡើង ដើម្បីបង្កើតសេចក្តីព្រាងទី១នៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ ការពិគ្រោះយោបល់ជាសាធារណៈជាច្រើន ជាមួយក្រុមអង្គការសង្គមស៊ីវិលនិងអ្នកជំនាញផ្នែកច្បាប់ បានបន្តធ្វើជាប្រចាំអស់រយៈពេលជិត ៣ឆ្នាំ ដែលជាលទ្ធផលបានបញ្ចប់និងដាក់ស្នើសេចក្តីព្រាងច្បាប់លើកដំបូងនៅខែកុម្ភៈឆ្នាំ ២០១៨ ។ ចាប់តាំងពីពេលនោះមក ក៏បានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យបន្តទៀត។

ការវិភាគនៃច្បាប់នេះនឹងផ្តោតលើសេចក្តីព្រាងចុងក្រោយ ដែលបានពិភាក្សារួចរាល់ជាមួយបណ្តាក្រសួងសំខាន់ៗនៅ ទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ២០-២១ ខែវិច្ឆិកាឆ្នាំ ២០១៩។ សេចក្តីព្រាងច្បាប់នេះត្រូវបានវាយតម្លៃដោយអ្នកជំនាញអន្តរជាតិមួយចំនួន រួមទាំងអង្គការសិទ្ធិមនុស្សអន្តរជាតិមាត្រា ១៩ ផងដែរ។

ការវិភាគច្បាប់នេះជាការយល់ឃើញរបស់អ្នកឯកទេសច្បាប់សិទ្ធិទទួលព័ត៌មាន ទោះបីជាមានការព្រមព្រៀងគ្នាជាច្រើនរវាងអ្នកឯកទេសច្បាប់ និងអ្នកជំនាញច្បាប់អន្តរជាតិផ្សេងទៀតដែលបានវាយតម្លៃច្បាប់នេះរួចហើយក៏ដោយ។ ទោះយ៉ាងណាក៏ដោយអ្នកឯកទេសច្បាប់ដែលបានរស់នៅក្នុងប្រទេសកម្ពុជា និងបានធ្វើការលើបញ្ហាទាំងនេះអស់រយៈពេលជិត ២០ ឆ្នាំហើយ

នោះក៏បានដឹងច្បាស់អំពីបរិបទរបស់ប្រទេសកម្ពុជាទាក់ទងនឹងធនធានបច្ចុប្បន្ន និងការអភិវឌ្ឍផ្នែកច្បាប់។ ទោះបីជាអ្នកឯកទេសច្បាប់នេះយល់ស្របនឹងអនុសាសន៍ដែលធ្វើឡើងដោយអ្នកជំនាញអន្តរជាតិក៏ដោយ អនុសាសន៍មួយចំនួន នោះបើគិតពីស្ថានភាពកម្ពុជាបច្ចុប្បន្ន គឺមិនទាន់ប្រាកដប្រជា ឬ អាចអនុវត្តបានទេនៅពេលនេះ។

ឧទាហរណ៍ស្តង់ដាមួយដែលអន្តរជាតិទទួលស្គាល់ថាសំខាន់ទាក់ទងនឹងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន គឺទាក់ទងនឹងបញ្ហាបណ្តឹងឧទ្ធរណ៍។ ជំពូកទី ៦ មាត្រា ២៦ និង ២៧ ពិពណ៌នាអំពីប្រព័ន្ធនៃបណ្តឹងឧទ្ធរណ៍សម្រាប់ការស្នើសុំព័ត៌មាន។ ទោះយ៉ាងណាក៏ដោយ មិនមានបទប្បញ្ញត្តិសម្រាប់ការបង្កើតស្នងការព័ត៌មានឯករាជ្យមួយ ឬគណៈកម្មាធិការព័ត៌មានឯករាជ្យជាច្រើន ដើម្បីពិចារណាលើបណ្តឹងឧទ្ធរណ៍និងជួយធានាឱ្យមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពឡើយ ហើយបើទោះជាបណ្តាប្រទេសជាង៨០ដែលមានច្បាប់ A2I បានចែងឲ្យមានស្នងការព័ត៌មានឯករាជ្យមួយ ឬគណៈកម្មាធិការព័តមានឯករាជ្យនេះ ក៏ដោយ។

ដោយសារតែកង្វះថវិកា ការបង្កើតស្ថាប័នថ្មី យន្តការនេះប្រហែលជាមិនអាចធ្វើទៅបានទេនៅ ក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ។ ទោះយ៉ាងណា គេអាចអនុវត្តប្រព័ន្ធការិយាល័យប្រជាពលរដ្ឋដែលមានស្រាប់(ដែលគេកំពុងតែបង្កើតនៅក្នុងប្រទេសកម្ពុជា) ចំពោះបណ្តឹងឧទ្ធរណ៍ យ៉ាងហោចណាស់រង់ចាំរហូតដល់ការបង្កើតស្ថាប័នស្នងការព័ត៌មាននាពេលអនាគត។

ដូច្នេះនៅក្នុងការវិភាគនេះ អ្នកឯកទេសច្បាប់ បានសំរេចផ្តោតលើផ្នែកសំខាន់ៗនៃសេចក្តីព្រាងចុងក្រោយដែលមានសារៈសំខាន់បំផុត និងជាអាទិភាពដែលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតជាមួយនឹងអនុសាសន៍សម្រាប់ធ្វើឱ្យប្រសើរឡើង។

**<u>អនុសាសន៍៖</u>**

### ជំពូកទី ១ មាត្រា ១

១. ដាក់បន្ថែមឯកសារយោងនៃសន្ធិសញ្ញាសិទ្ធិមនុស្សនិងឯកសាររបស់ពាក់ព័ន្ធនឹងសិទ្ធិទទួល ព័តមាន រួមទាំងមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) ក៏ដូចជាយោងតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

២- រាប់បញ្ចូលការសន្មតទុកជាមុន ឬអាទិភាពនៃការបើកចំហព័ត៌មានទាំងស្រុងទាក់ទងនឹងការអនុវត្តច្បាប់នេះ។

**ជំពូកទី ១ មាត្រា ៣ និង ៤**

ពិនិត្យ និងកែតម្រូវ មាត្រា ៣ និងមាត្រា ៤ ដើម្បីធានាថាមាត្រាទាំងនេះអាចអនុវត្តបានគ្រប់ស្ថាប័នសាធារណៈទាំងអស់រួមទាំង ស្ថាប័នអនុវត្តមុខងារសាធារណៈដូចជាតុលាការ ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នធម្មនុញ្ញពិសេស ក៏ដូចជាស្ថាប័នឯកជនដែលប្រើប្រាស់ថវិការដ្ឋ។

**ជំពូកទី ១ មាត្រា ៤**

១. ពិនិត្យ និងកែតម្រូវ ដើម្បីដាក់បញ្ចូលរាល់ឯកសារទាំងអស់ដែលស្ថិតនៅក្រោមការកាន់កាប់របស់ស្ថាប័នសាធារណៈ និងមិនមែនត្រឹមតែឯកសារ" ផ្លូវការ" ប៉ុណ្ណោះទេ។

**ជំពូកទី ៣ មាត្រា ១១**

១. ពិនិត្យ និងកែតម្រូវ មាត្រា ១១ ដោយលុបចោលនូវលក្ខខណ្ឌដែលតម្រូវឲ្យ អ្នកស្នើសុំព័ត៌មានបង្ហាញព័ត៌មានពីយែនឌ័រ (ភេទ) អាយុ សញ្ជាតិ និងមុខរបរ។

**ជំពូកទី ៣ មាត្រា ១៣**

១. ពិនិត្យ និងកែតម្រូវ មាត្រា ១៣ ដោយកាត់បន្ថយរយៈពេលនៃការឆ្លើយតបចំពោះការស្នើសុំព័ត៌មាន ពី ១៥ ថ្ងៃទៅ ៥ ថ្ងៃវិញ។ នៅក្នុងសេចក្តីព្រាងច្បាប់មុនៗ ពេលវេលាឆ្លើយតបត្រូវបានកត់សម្គាល់ឃើញថាមានរយៈពេល ៥ ថ្ងៃ។

**ជំពូកទី ៣ មាត្រា ១៥**

១. លុបចំណុចទី៤ នៃមាត្រា១៥ ទាក់ទងនឹងដែនកំណត់ ៤០ ថ្ងៃ មុនការស្នើសុំម្តងទៀតកើតឡើង។ ការកំណត់បែបនេះមិនចាំបាច់ទេ។ អ្នកស្នើសុំគួរតែមានសេរីភាពក្នុងការស្នើសុំម្តងហើយម្តងទៀតដោយគ្មានពេលវេលាកំណត់។

**ជំពូកទី ៤ មាត្រា ២០**

១. រាប់បញ្ចូលការធ្វើតេស្តសាកល្បង ៣ ផ្នែកជាគោលការណ៍ទូទៅនៃមាត្រា ២០ ។ ផ្នែកដែលអាចមានដូចខាងក្រោម៖

ស្ថាប័នសាធារណៈអាចបដិសេធផ្តល់ព័ត៌មានដល់អ្នកស្នើសុំនៅពេលដែល**គ្រប់លក្ខខណ្ឌ**ទាំងបីត្រូវបានបំពេញដូចខាងក្រោម:

- ព័ត៌មានដែលស្ថិតនៅក្រោមការលើកលែងមួយឬច្រើននៃករណីលើកលែងដែលបានចែងនៅក្នុងមាត្រានេះ។
- ប្រសិនបើព័ត៌មានដែលបញ្ចេញនោះ មានមហន្តរាយធ្ងន់ធ្ងរ និងអាចបង្កឲ្យខូចខាតដល់ផលប្រយោជន៍ដែលមានការការពារពីច្បាប់
- ការខូចខាតដល់ផលប្រយោជន៍ដែលមានការការពារពីច្បាប់នេះ ត្រូវតែធំជាងផលប្រយោជន៍សាធារណៈក្នុងការបញ្ចេញព័ត៌មាន។

២. លុបចំណុចទី៧ នៃមាត្រា ២០៖ "ព័ត៌មានសម្ងាត់ផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិហាមឃាត់" ។ គឺមានលក្ខណៈទូលំទូលាយពេកនិងខ្វះភាពជាក់លាក់។

**ជំពូកទី ៥ មាត្រា ២៤**

១. ពិនិត្យ និងកែតម្រូវ មាត្រា ២៤ ដើម្បីការពារប្រភពព័ត៌មានដែលបញ្ចេញឬលាតត្រដាងព័ត៌មានស្តីពីការប្រព្រឹត្តខុស រួមមានបទព្រហ្មទណ្ឌ មិនបានបំពេញកាតព្វកិច្ចផ្លូវច្បាប់ អំពើពុករលួយឬភាពមិនស្មោះត្រង់ការគ្រប់គ្រងមិនល្អឬកង្វះអភិបាលកិច្ចល្អដែលទាក់ទងនឹងស្ថាប័នសាធារណៈណាមួយ និងការគំរាមកំហែងដល់សុខភាពសាធារណៈ និងការគំរាមកំហែងដល់បរិស្ថាន ។

**ជំពូកទី ៧ មាត្រា ២៩ និង ៣០**

លុបមាត្រា ២៩ និង ៣០។ មាត្រាទាំងនេះ មិនពាក់ព័ន្ធនឹងច្បាប់នេះឡើយ។ នៅក្នុងក្រមព្រហ្មទណ្ឌ មានបទប្បញ្ញត្តិជាច្រើនហើយ ដែលអាចអនុវត្តក្នុងការដោះស្រាយករណីបែបនេះ។

**ជំពូកទី ៩**

១. សូមស្រង់មាត្រា ៣៧ដែលមាននៅក្នុងសេចក្តីព្រាងមុន ត្រឡប់មកវិញ៖
"ច្បាប់នេះ ត្រូវមានអាទិភាព ប្រសិនបើបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតមិនស្របនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ" ។

មាត្រានេះចែងច្បាស់អំពីអាទិភាពនៃច្បាប់ដែលជាផ្នែកមួយនៃក្របខណ្ឌច្បាប់និងស្ថាប័នច្បាប់នៅកម្ពុជា។

# តារាងមាតិកា


ទំព័រ

**សេចក្តីសង្ខេបរួម** 1

**សិទ្ធិទទួលព័ត៌មាន៖ បទដ្ឋានច្បាប់អន្តរជាតិ** 5

**ការទទួលស្គាល់ជាសកលនិងនៅថ្នាក់តំបន់នៃសិទ្ធិទទួលព័ត៌មាន** 7

**សិទ្ធិទទួលព័ត៌មាននៅកម្ពុជា** 7

**ការវិភាគលើសេចក្តីព្រាងច្បាប់ (សេចក្តីព្រាងចុងក្រោយខែវិច្ឆិកាឆ្នាំ ២០១៩)** 9


## សិទ្ធិទទួលព័ត៌មាន៖ បទដ្ឋានច្បាប់អន្តរជាតិ

សិទ្ធិក្នុងការទទួលបានព័ត៌មានដែលគ្រប់គ្រងដោយស្ថាប័នសាធារណៈ(ក៏ត្រូវបានគេស្គាល់ផងដែរថាជា“ សេរីភាពព័ត៌មាន” ឬ“ សិទ្ធិដឹង”) ដែលច្បាប់អន្តរជាតិបានទទួលស្គាល់ជាសិទ្ធិមូលដ្ឋានរបស់មនុស្ស។ ទោះបីគេមិនបានដាក់ថា “ សិទ្ធិទទួលព័ត៌មាន” យ៉ាងជាក់លាក់នៅក្នុងដំណាក់កាលដំបូងនៃសន្ធិសញ្ញាសិទ្ធិមនុស្សនិងឯកសារពាក់ព័ន្ធរបស់វាក៏ដោយ ប៉ុន្តែឥឡូវនេះសិទ្ធិនេះត្រូវបានទទួលស្គាល់ជាទូទៅថាជាផ្នែកមួយនៃសិទ្ធិជាមូលដ្ឋាននៃសេរីភាពក្នុងការបញ្ចេញមតិដែលរួមទាំងសិទ្ធិក្នុងការស្វែងរក ការទទួលបាននិងការផ្សព្វផ្សាយព័ត៌មាន។ មាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ចែងថា៖មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងការសម្តែងមតិ។ សិទ្ធិនេះរួមបញ្ចូលទាំង*សិទ្ធិក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែកនិងសេរីភាពក្នុងការស្វែងរក ការទទួលនិងការផ្សព្វផ្សាយព័ត៌មាននិងគំនិតនានា* តាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយ និងដោយមិនគិតពីព្រំដែនឡើយ។ (ការសង្កត់ន័យធ្ងន់លើអក្សរទ្រេត)

ទោះបីជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) មិនដាក់កាតព្វកិច្ចដោយផ្ទាល់លើរដ្ឋនានាក៏ដោយ ផ្នែកខ្លះ រួមទាំងមាត្រា ១៩ ឥឡូវនេះត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) ដែលមិនដូចសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) គឺជាសន្ធិសញ្ញាដាក់កាតព្វកិច្ចច្បាប់ជាផ្លូវការ ដែលត្រូវបានអនុម័តដោយប្រទេសចំនួន ១៧០ រួមទាំងប្រទេសកម្ពុជាដើម្បីធានានូវសេរីភាពខាងការបញ្ចេញមតិនិងសិទ្ធិទទួលបានព័ត៌មានដោយប្រើភាសាស្រដៀងនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)[1] ។

ក្នុងឆ្នាំ ២០១១ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានបកស្រាយអំពីវិសាលភាពនិងដែនកំណត់នៃសិទ្ធិទទួលបានព័ត៌មានដោយចែងថាមាត្រា ១៩ នៃ ICCPR ធានាពីសិទ្ធិទទួលព័ត៌មានដែលកាន់កាប់ដោយរដ្ឋាភិបាល។ គណៈកម្មាធិការតម្រូវឲ្យរដ្ឋភាគីផ្សព្វផ្សាយព័ត៌មានជាមុនទោះមិនមានការស្នើសុំក៏ដោយ ដើម្បីផលប្រយោជន៍សាធារណជន និងធានាថាការទទួលបានព័ត៌មាន "មានភាពងាយស្រួល ទាន់ពេលវេលា មានប្រសិទ្ធិភាព និងអាចយកទៅប្រើប្រាស់បាន។" លើសពីនេះទៀត រដ្ឋភាគីត្រូវតែចាត់ "វិធានចាំបាច់នានា" ដូចជា ច្បាប់ពាក់ព័ន្ធដើម្បីធានាដល់ការអនុវត្តសិទ្ធិទទួលព័ត៌មាន។ ថ្លៃឈ្នួលនៃការស្នើសុំព័ត៌មានត្រូវតែដាក់កម្រិតទាបបំផុតការឆ្លើយតបព័ត៌មានត្រូវតែទាន់ពេលវេលា អាជ្ញាធរត្រូវតែផ្តល់ការពន្យល់យ៉ាងជាក់ច្បាស់ចំពោះព័ត៌មានណាដែលមិនអាចបញ្ចេញបាន ហើយរដ្ឋភាគីត្រូវតែបង្កើតយន្តការបណ្តឹងឧទ្ធរណ៍[2]។

សិទ្ធិទទួលបានព័ត៌មានក៏ត្រូវបានគេទទួលស្គាល់ថាជាផ្នែកមួយនៃក្របខណ្ឌច្បាប់អន្តរជាតិទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ចនិងសង្គមដែលកំណត់ដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌ (ICESCR) ។ សិទ្ធិទទួលបានព័ត៌មាន (A2I) ត្រូវបានគេចាត់ឲ្យស្ថិតនៅក្រោមច្បាប់អន្តរជាតិថាជា "សិទ្ធិដែលអាចធ្វើទៅបាន" ជាសិទ្ធិគាំទ្រឬជួយប្រជាពលរដ្ឋឱ្យសម្រេចបាននូវសិទ្ធិមនុស្សផ្សេងទៀតឲ្យកាន់តែប្រសើរឡើងនិងដើម្បីជួយជំរុញឲ្យមានកិច្ចពិគ្រោះ យោបល់ធំៗអំពីប្រទេសជាតិ និងការចូលរួមលើបញ្ហាគោលនយោបាយនិងបញ្ហារដ្ឋាភិបាល។ សិទ្ធិទទួលព័ត៌មាន (A2I) ជាផ្នែកមួយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (SDGs)។ បណ្តាប្រទេសជាសមាជិករបស់អង្គការសហប្រជាជាតិ

[1] ដំណោះស្រាយមហាសន្និបាទអង្គការសហប្រជាជាតិ ២២០០(XXII) ថ្ងៃ១៥ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាននៅថ្ងៃ២៣ ខែមីនា ឆ្នាំ១៩៧៦។

[2] គណៈកម្មាធិការអង្គការសហប្រជាជាតិ អនុសាស៍ទូទៅលេខ ៣៤ មាត្រា ១៩ៈ សេរីភាពនៃការបញ្ចេញមតិ និងសម្តែងមតិ (២០១១) http://www.refworld.org/pdfid/4ed34b562.pdf.

បានឯកភាពគ្នាបង្កើតគោលដៅជាក់លាក់ដែលរដ្ឋនានាធានា " ការទទួលបានព័ត៌មានជាសាធារណៈ" ។ អង្គការសហប្រជាជាតិក៏បានបញ្ជាក់ដែរថាសិទ្ធិទទួលព័ត៌មានគឺចាំបាច់ដើម្បីធានាសិទ្ធិក្នុងការទទួលបានទឹកស្អាត សេវាសុខភាព និងការអប់រំ។ សិទ្ធិទទួលបានព័ត៌មានក៏ត្រូវបានលើកឡើងជាពិសេសនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារនិងអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ សិទ្ធិទទួលព័ត៌មាន ក៏ត្រូវបានទទួលស្គាល់ផងដែរថាជាប្រភពដ៏សំខាន់ក្នុងការការពារបរិស្ថាន។ សិទ្ធិនេះក៏ត្រូវបានរកឃើញនៅក្នុងសន្ធិសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងការបំពុលបរិស្ថាននិងការប្រែប្រួលអាកាសធាតុនិងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ (UNCAC) ។

## ការទទួលស្គាល់ជាសកលនិងនៅថ្នាក់តំបន់នៃសិទ្ធិទទួលព័ត៌មាន

ឥឡូវនេះនៅក្នុងប្រទេសជាង១២០ជុំវិញពិភពលោកបានអនុម័តសិទ្ធិទទួលព័តមានចូលជាច្បាប់ឬគោលនយោបាយនៅក្នុងប្រទេសរបស់ពួកគេ (៦១ ភាគរយនៃរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ) រួមមានសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ ជប៉ុន ចិន រុស្ស៊ី កូរ៉េខាងត្បូង និងឥណ្ឌា ។ នៅក្នុងអាស៊ានមាន ឥណ្ឌូនេស៊ី ថៃ និងវៀតណាមបានអនុម័តសិទ្ធិទទួលព័តមានចូល ជាគោលនយោបាយនិងច្បាប់ជាតិរបស់ពួកគេ ។ លើសពីនេះប្រទេសចំនួន ៩០ (រួមទាំងសាធារណរដ្ឋហ្វីលីពីននៅអាស៊ាន)បានអនុម័តការធានាសិទ្ធិនេះក្នុងរដ្ឋធម្មនុញ្ញយ៉ាងជាក់លាក់។ ច្បាប់សេរីភាពសារព័ត៌មានរបស់ស៊ុយអែតដែលត្រូវបានអនុម័តក្នុងឆ្នាំ ១៧៦៦ ជាទូទៅ គេគិតថាជាច្បាប់សិទ្ធិទទួលព័ត៌មានដែលមានវ័យចំណាស់ជាងគេ[3]។ ដោយយោងតាមឧទាហរណ៍របស់រដ្ឋជាច្រើន ចំនួនស្ថាប័នអន្តររដ្ឋាភិបាលនិងស្ថាប័នអន្តរជាតិ ដូចជាសហភាពអឺរ៉ុប កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី) ធនាគារពិភពលោកនិងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក៏បានអនុម័តគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មានផងដែរ។ A2Iក៏ត្រូវបានគេទទួលស្គាល់ម្តងហើយម្តងទៀតនៅក្នុងសេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសិទ្ធិមនុស្ស និងនៅក្នុងអនុសាសន៍ទូទៅ និងករណីនានានៅចំពោះមុខគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនិងគណៈកម្មាធិការរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមនិងវប្បធម៌។

## សិទ្ធិទទួលព័ត៌មាននៅកម្ពុជា

ទោះបីជាបច្ចុប្បន្ននេះមិនមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ជាក់លាក់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនៅក្នុងឆ្នាំ ២០០៤ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់ជាផ្លូវការ

[3] "គោលការណ៍នៃការទទួលបានព័ត៌មានសាធារណៈ" http://www.sweden.gov.se/5b/d/2184/a/15521

នូវតម្រូវការនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន"ដើម្បីបង្កើតរដ្ឋាភិបាលប្រកបដោយតម្លាភាពកាត់បន្ថយអំពើពុករលួយនិងលើកកម្ពស់ទំនុកចិត្តលើរដ្ឋាភិបាលពីសំណាក់ប្រជាពលរដ្ឋកម្ពុជា។"[4] គេបានកំណត់គោលដៅមួយ(ដោយមានការយល់ព្រមពីម្ចាស់ជំនួយ) ដើម្បីបង្កើតក្របខណ្ឌគោលនយោបាយស្តីពីការទទួលបានព័ត៌មានជាក់លាក់មួយ ដែលនឹងឈានទៅដល់សេចក្តីព្រាងច្បាប់ និងការអនុម័តច្បាប់មួយដែលអាចអនុវត្តបាន។

បន្ទាប់ពីសិក្ខាសាលានិងសន្និសីទសាធារណៈជាច្រើន អស់រយៈពេល ៣ ឆ្នាំ ដែលមានការចូល រួមពីមន្ត្រីរដ្ឋាភិបាល សមាជិកអង្គការសង្គមស៊ីវិល អ្នកជំនាញច្បាប់ និងសាធារណៈជនទូទៅមកទីស្តីការគណៈរដ្ឋមន្ត្រីបានចាត់តាំងក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ចឲ្យបង្កើតឯកសារព្រាងគោលនយោបាយរបស់រដ្ឋាភិបាលស្តីពីសិទ្ធិទទួលព័ត៌មានដែលនឹងត្រូវមានមុនពេលពង្រាងសេចក្តីព្រាងច្បាប់ថ្នាក់ជាតិស្តីពីសិទ្ធិទទួលព័ត៌មាន។ ឯកសារព្រាងគោលនយោបាយរបស់រដ្ឋាភិបាលស្តីពីសិទ្ធិទទួលព័ត៌មាននេះត្រូវបានបញ្ចប់រួចជាស្រេចនៅចុងខែសីហា ឆ្នាំ២០០៧។

បន្ទាប់មកនៅខែឧសភាឆ្នាំ ២០១៣ ស្ថានទូតស៊ុយអែតសហការជាមួយអង្គការយូណេស្កូបានឧបត្ថម្ភថវិកាសម្រាប់រៀបចំ " សន្និសីទជាតិស្តីពីសិទ្ធិទទួលព័ត៌មាន" ដែលរួមមានការចូលរួមរបស់ក្រុមសង្គមស៊ីវិលជាច្រើន មន្ត្រីរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាននិងអ្នកជំនាញច្បាប់។ បន្ទាប់មកនៅថ្ងៃទី ៣០ ខែឧសភាឆ្នាំ ២០១៤ យូណេស្កូ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយក្រសួងព័ត៌មាននិងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) ដើម្បីសហការលើគម្រោងមួយដែលនឹងនាំទៅដល់ការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានថ្នាក់ជាតិ។ នៅឆ្នាំ ២០១៥ គេបានបង្កើតឡើងនូវក្រុមការងារបច្ចេកទេស ដែលរួមមានមន្ត្រីក្រសួងព័ត៌មាន មន្ត្រីយូណេស្កូតំណាងសង្គមស៊ីវិលនិងអ្នកជំនាញច្បាប់ ដើម្បីបង្កើតសេចក្តីព្រាងច្បាប់លើកទី១។ ការពិគ្រោះយោបល់ជាសាធារណៈជាមួយក្រុមសង្គមស៊ីវិល និងអ្នកជំនាញផ្នែកច្បាប់បានបន្តជាប្រចាំអស់រយៈពេលជិត៣ឆ្នាំ ដែលជាលទ្ធផលបានបញ្ចប់និងដាក់ស្នើសេចក្តីព្រាងច្បាប់លើកទី១កាលពីខែកុម្ភៈឆ្នាំ ២០១៨ ។ ចាប់តាំងពីពេលនោះមក សេចក្តីព្រាងច្បាប់នេះ បានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យបន្តទៀត។ ទីស្តីការគណៈរដ្ឋមន្ត្រីកាលពីខែវិច្ឆិកាឆ្នាំ ២០១៩ ក៏បានបញ្ចប់សេចក្តីព្រាងច្បាប់ចុងក្រោយដោយមានការកែប្រែជាច្រើនពីសេចក្តីព្រាងលើកដំបូង។

---

[4]" ក្របខណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៍មានសម្រាប់កម្ពុជា"ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៃព្រះរាជាណាចក្រកម្ពុជា

## ការវិភាគលើសេចក្តីព្រាងច្បាប់ (សេចក្តីព្រាងចុងក្រោយខែវិច្ឆិកាឆ្នាំ ២០១៩)

ការវិភាគនៃច្បាប់នេះនឹងផ្តោតលើសេចក្តីព្រាងចុងក្រោយដែលចេញដោយក្រសួងព័ត៌មាន ចុះថ្ងៃទី ២០-២១ ខែវិច្ឆិកាឆ្នាំ ២០១៩ ។ សេចក្តីព្រាងច្បាប់នេះត្រូវបានវាយតម្លៃដោយអ្នកជំនាញអន្តរជាតិមួយចំនួន រួមទាំងអង្គការសិទ្ធិមនុស្សអន្តរជាតិមាត្រា ១៩ ។

ការវិភាគច្បាប់នេះជារបស់អ្នកឯកទេសច្បាប់ទាំងស្រុង ទោះបីមានការព្រមព្រៀងគ្នាច្រើនរវាងអ្នកឯកទេសច្បាប់និងអ្នកជំនាញច្បាប់អន្តរជាតិផ្សេងទៀតដែលបានវាយតម្លៃច្បាប់នេះរួចហើយក៏ដោយ។ ទោះយ៉ាងណាក៏ដោយឯកទេសទេសច្បាប់ដែលបានរស់នៅក្នុងប្រទេសកម្ពុជាហើយបានធ្វើការលើបញ្ហាទាំងនេះអស់រយៈពេលជិត ២០ ឆ្នាំហើយនោះ ក៏បានដឹងច្បាស់អំពីបរិបទរបស់ប្រទេសកម្ពុជាទាក់ទងនឹងធនធានបច្ចុប្បន្ន និងការអភិវឌ្ឍផ្នែកច្បាប់។ ទោះបីជាអ្នកឯកទេសច្បាប់នេះយល់ស្របនឹងអនុសាសន៍ដែលធ្វើឡើងដោយអ្នកជំនាញអន្តរជាតិក៏ដោយអនុសាសន៍មួយចំនួននេះ បើគិតពីស្ថានភាពកម្ពុជាបច្ចុប្បន្ន គឺមិនទាន់ប្រាកដឬ អាចធ្វើទៅបានទេនៅពេលនេះ។

ដូច្នេះអ្នកឯកទេសច្បាប់បានសំរេចផ្តោតលើផ្នែកដូចខាងក្រោម ដែលជាចំណុចសំខាន់បំផុតនិងជាអាទិភាពខ្ពស់បំផុតដោយមានអនុសាសន៍សម្រាប់ធ្វើឲ្យប្រសើរឡើង៖

### ជំពូកទី ១ មាត្រា ១

អត្ថបទចុងក្រោយនៃមាត្រា ១ បានលុបឯកសារយោងរបស់មាត្រា ១៩ នៃសេចក្តីប្រកាសជា សកលស្តីពីសិទ្ធិមនុស្ស។

**សេចក្តីព្រាងខែវិច្ឆិកាឆ្នាំ ២០១៩៖**

**មាត្រា ១.**

គោលបំណងនៃច្បាប់នេះគឺដើម្បីធានានូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈនិងទាមទារឲ្យស្ថាប័នសាធារណៈបំពេញកាតព្វកិច្ចឲ្យបានពេញលេញក្នុងការផ្តល់និងផ្សព្វផ្សាយព័ត៌មានជាអតិបរមាដល់សាធារណជន។

**សេចក្តីព្រាងពីមុន៖**

**មាត្រា ១.** គោលបំណងនៃច្បាប់នេះគឺដើម្បីធានានូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន។ ច្បាប់នេះចែងអំពីកាតព្វកិច្ចរបស់ស្ថាប័នសាធារណៈក្នុងការផ្តល់និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ**ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។**

**មតិយោបល់**

វាមានសារៈសំខាន់ណាស់នៅជំណាក់កាលដំបូងនៃច្បាប់នេះ ត្រូវយោងទៅលើមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលជាផ្នែកគ្រឹះនៃក្របខណ្ឌច្បាប់សិទ្ធិមនុស្សអន្តរជាតិហើយដែលប្រទេសកម្ពុជាបានប្តេជ្ញាចិត្តដើម្បីធ្វើតាមពីមុនមក។ ការដាក់បញ្ចូលឯកសារយោងនេះក៏អាចបង្ហាញផងដែរថាប្រទេសកម្ពុជាទទួលស្គាល់សិទ្ធិទទួលព័ត៌មានជាសិទ្ធិមនុស្ស។

លើសពីនេះមាត្រា១គួរតែរួមបញ្ចូលនូវការប៉ាន់ប្រមាណទុកជាមុននៃការបើកចំហព័ត៌មានទាំងស្រុង។ នេះមានន័យថាការបើកចំហព័ត៌មានទាំងស្រុងត្រូវតែជាអាទិភាពនិងត្រូវតែជាកាតព្វកិច្ច របស់រដ្ឋាភិបាល ប្រសិនបើមិនមានការលើកលែងឬស្ថានភាពពិសេសណាមួយឡើយ។ ការប៉ានប្រមាណទុកជាមុននៃការបើកចំហព័ត៌មានទាំងស្រុង គឺជាគោលការណ៍សំខាន់នៃនិយាមសិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងតម្លាភាពនិងសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន។

**អនុសាសន៍សម្រាប់មាត្រា ១៖**

១. ដាក់បន្ថែមឯកសារយោងនៃសន្ធិសញ្ញាសិទ្ធិមនុស្សនិងឯកសាររបស់វាពាក់ព័ន្ធនឹងសិទ្ធិទទូលព័តមានរួមទាំងមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) ក៏ដូចជាយោងតាមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

២- រាប់បញ្ចូលការសន្មតទុកជាមុន ឬអាទិភាពនៃកាបើកចំហរព័ត៌មានទាំងស្រុងទាក់ទងនឹងការអនុវត្តច្បាប់នេះ។

# ជំពូកទី ១ មាត្រា ៣ និង ៤

## សេចក្តីព្រាងខែវិច្ឆិកាឆ្នាំ ២០១៩៖

**មាត្រា ៣.** ច្បាប់នេះអនុវត្តចំពោះគ្រប់ប្រភេទនៃព័ត៌មានដែលស្ថាប័នសាធារណៈត្រូវផ្តល់ឲ្យទាំងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែព័ត៌មានសម្ងាត់ជាក់លាក់មួយចំនួនដែលមានចែងក្នុងច្បាប់នេះ។

**មាត្រា ៤.**

ស្ថាប័នសាធារណៈ ៖ សំដៅទៅលើក្រសួងស្ថាប័នឬអង្គភាពផ្សេងទៀតដែលបំពេញមុខងារសាធារណៈរួមមានរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបង្កើតឡើងដោយច្បាប់ ឬ / និងបទប្បញ្ញត្តិផ្សេងទៀត។

## មតិយោបល់

មាត្រា ៣ ចែងថាសេចក្តីព្រាងច្បាប់នេះអនុវត្តចំពោះអង្គភាពរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា ៤ បានកំណត់ស្ថាប័នសាធារណៈថាជា" ក្រសួងស្ថាប័នឬអង្គភាពផ្សេងទៀតដែលបំពេញមុខងារសាធារណៈ រួមមានរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបង្កើតឡើងដោយច្បាប់ឬ / និងបទប្បញ្ញត្តិផ្សេងទៀត"។

ផ្អែកលើភាសាជាក់លាក់នៃមាត្រា ៣ និង ៤ ច្បាប់នេះអនុវត្តតែចំពោះស្ថាប័នរដ្ឋបាល និងស្ថាប័នដទៃទៀតដែលបង្កើតឡើងដោយច្បាប់ឬបទបញ្ញា។វាមិនរាប់បញ្ចូលទាំងស្ថាប័នតុលាការ និងសាខានីតិប្បញ្ញត្តិ (រដ្ឋសភាឬព្រឹទ្ធសភា) ឬស្ថាប័នឯកជនដែលបំពេញមុខងារសាធារណៈ។ អង្គភាពរដ្ឋធម្មនុញ្ញ (ឧទាហរណ៍ដូចជាក្រុមប្រឹក្សាធម្មនុញ្ញ) មិនត្រូវបានរាប់បញ្ចូលជាពិសេសនៅក្នុងវិសាលភាពនៃការអនុវត្តច្បាប់ឡើយ។ យោងតាមស្តង់ដារច្បាប់អន្តរជាតិដែលត្រូវបានទទួលយកនាពេលបច្ចុប្បន្នសិទ្ធិទទួលបានព័ត៌មានត្រូវអនុវត្តចំពោះស្ថាប័នសាធារណៈនិងស្ថាប័នឯកជនដោយប្រើប្រាស់ថវិកាសាធារណៈ។ បទប្បញ្ញត្តិនេះផ្តល់និយមន័យតូចចង្អៀតពេក។

## អនុសាសន៍សម្រាប់មាត្រា ៣ និង ៤៖

ពិនិត្យ និងកែតម្រូវ មាត្រា ៣ និងមាត្រា ៤ ដើម្បីធានាថាមាត្រាទាំងនេះអាចអនុត្តបានគ្រប់ស្ថាប័នសាធារណៈទាំងអស់រួមទាំង ស្ថាប័នអនុវត្តមុខងារសាធារណៈដូចជាតុលាការ ស្ថាប័ននីតិប្បញ្ញត្តិ និងអង្គភាពរដ្ឋធម្មនុញ្ញពិសេស ក៏ដូចជាស្ថាប័នឯកជនដោយប្រើប្រាស់ថវិកាសាធារណៈ។

## ជំពូកទី ១ មាត្រា ៤

**សេចក្តីព្រាងខែវិច្ឆិកាឆ្នាំ ២០១៩៖**

**មាត្រា ៤.**

ពាក្យបច្ចេកទេសដែលត្រូវបានប្រើនៅក្នុងច្បាប់នេះរួមមានដូចខាងក្រោម៖

- ព័ត៌មាន ៖ សំដៅទៅលើរាល់ឯកសារនិងទម្រង់ទាំងអស់នៃឯកសារផ្លូវការក្រោមកម្មសិទ្ធិរបស់ស្ថាប័នសាធារណៈ។
- ព័ត៌មានសាធារណៈ ៖ សំដៅទៅលើព័ត៌មានដែលស្ថាប័នសាធារណៈត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សាធារណជន។

**មតិយោបល់**

និយមន័យទាំងនេះ គួរតែត្រូវបានគេបញ្ជាក់ឲ្យកាន់តែច្បាស់ ដោយយោងទៅលើព័ត៌មានទាំងអស់ដែលកាន់កាប់ដោយស្ថាប័នសាធារណៈ និងមិនត្រឹមតែឯកសារផ្លូវការប៉ុណ្ណោះទេ។ នេះអាចធ្វើឲ្យមន្ត្រីសាធារណៈមានការចាត់ថ្នាក់ឯកសារជា" មិនផ្លូវការ" ដើម្បីកំណត់ឬបដិសេធមិនឲ្យ សាធារណជនទទួលបានព័ត៌មាន។

**អនុសាសន៍សម្រាប់មាត្រា ៤៖**

ពិនិត្យ និងកែតម្រូវ ដើម្បីដាក់បញ្ចូលរាល់ឯកសារ***ទាំងអស់***ដែលស្ថិតនៅក្រោមការកាន់កាប់របស់ស្ថាប័នសាធារណៈ និងមិនមែនត្រឹមតែឯកសារ" ផ្លូវការ" ប៉ុណ្ណោះទេ។

## ជំពូកទី ៣ មាត្រា ១០ ១១ និង ១៥

**សេចក្តីព្រាងខែវិច្ឆិកាឆ្នាំ ២០១៩៖**

**មាត្រា ៥.**

មនុស្សគ្រប់រូបមានសិទ្ធិនិងសេរីភាពក្នុងការទទួលបានព័ត៌មានដែលគ្រប់គ្រងដោយស្ថាប័នសាធារណៈក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

**មាត្រា ១០.**

មនុស្សគ្រប់រូបមិនថាជារូបវន្តបុគ្គលឬនីតិបុគ្គល ត្រូវមានសិទ្ធិស្នើសុំព័ត៌មានគ្រប់ប្រភេទទាំងអស់ពីស្ថាប័នសាធារណៈទាំងឡាយដោយគ្មានការរើសអើង។

**មាត្រា ១១.**

ការស្នើសុំព័ត៌មានត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានការពិពណ៌នាលំអិតអំពីព័ត៌មានដែលបានស្នើសុំនិងទម្រង់ឯកសារដែលត្រូវបញ្ជូនទៅស្ថាប័នសាធារណៈ។ នីតិវិធីនិងបែបបទសម្រាប់ការស្នើសុំព័ត៌មានត្រូវបានកំណត់ដូចខាងក្រោម៖

១. បែបបទផ្លូវការសម្រាប់ស្នើសុំព័ត៌មាន៖

- ឈ្មោះ ភេទ អាយុ សញ្ជាតិ មុខរបរ។
- អាសយដ្ឋានបច្ចុប្បន្ននិង / ឬអាសយដ្ឋានអេឡិចត្រូនិច (បើមាន)
- បរិយាយព័ត៌មានលំអិតដែលត្រូវស្នើសុំ។

**មាត្រា ១៣.**

មន្ត្រីទទួលបន្ទុកព័ត៌មានត្រូវពិនិត្យមើលសំណើព័ត៌មានភ្លាមៗនិងផ្តល់ការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំរបស់ខ្លួនដោយជូនដំណឹងប្រសិនបើមានឬគ្មានព័ត៌មានដែលបានស្នើសុំឬប្រសិនបើវាជាព័ត៌មានសម្ងាត់ដែលត្រូវបានហាមឃាត់ដោយច្បាប់មិនឲ្យបង្ហាញជាសាធារណៈ។ ការឆ្លើយតបនឹងត្រូវផ្តល់ឱ្យមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលទទួលបានការស្នើសុំ។

**មាត្រា ១៥.**

ស្ថាប័នសាធារណៈអាចបដិសេធផ្តល់ព័ត៌មានដល់អ្នកស្នើសុំដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

១. ព័ត៌មានដែលបានស្នើសុំត្រូវបានហាមឃាត់ដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់។

២. អ្នកស្នើសុំដែលមិនបំពេញពាក្យសុំឲ្យបានពេញលេញដូចមានចែងក្នុងមាត្រា ១១នៃច្បាប់នេះ

៣. អ្នកស្នើសុំដែលបង្កផលលំបាកដល់ប្រតិបត្តិការរបស់ស្ថាប័នសាធារណៈនិង / ឬមន្ត្រីនៃស្ថាប័នសាធារណៈឬមន្ត្រីទទួលបន្ទុកព័ត៌មាន។

៤.ព័ត៌មានដែលបានស្នើសុំហើយ ត្រូវរង់ចាំរយៈពេលពេល ៤០ (សែសិប) ថ្ងៃ ទើបអាចស្នើសុំពីស្ថាប័នសាធារណៈដដែលបាន ។

**មតិយោបល់**

មាត្រា ៥ និង ១០ ចែងថាសិទ្ធិទទួលព័ត៌មានអនុវត្តចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលដោយគ្មានការរើសអើង។ នេះមានន័យថាស្ថាប័នសាធារណៈត្រូវជួយអ្នកស្នើសុំឱ្យទទួលបានព័ត៌មាន

ដោយមិនគិតពីជនជាតិភាគតិច យែនឌ័រ ឬស្ថានភាពសង្គមឬស្ថានភាពសេដ្ឋកិច្ចរបស់អ្នកស្នើសុំឡើយ។ទោះយ៉ាងណាមាត្រា ១១ បានចែងអំពីលក្ខខណ្ឌមួយចំនួនដែលត្រូវបំពេញដើម្បីស្នើសុំ។ តម្រូវការទាំងនេះទាក់ទងនឹងភេទ (ភេទ) សញ្ជាតិ អាយុ និងមុខរបរ គឺមិនចាំបាច់ទេ។ លក្ខខណ្ឌទាំងនេះមិនត្រូវគ្នានឹងបទដ្ឋានច្បាប់អន្តរជាតិទាក់ទងនឹងគោលការណ៍មិនរើសអើងឡើយ។

នៅក្នុងមាត្រា ១៣ សេចក្តីព្រាងមុន បានចែងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ មិនមានហេតុផលច្បាស់លាស់ឬហេតុផលជាក់លាក់ណាមួយដែលត្រូវបានផ្តល់សម្រាប់ការបង្កើនពេលវេលាដល់ ១៥ (ដប់ប្រាំ) ថ្ងៃធ្វើការនៅក្នុងសេចក្តីព្រាងចុងក្រោយទេ។នៅក្នុងមាត្រា ១៥ ត្រូវមានការកំណត់រយៈពេល ៤០ ថ្ងៃមុនពេលមានការស្នើសុំម្តងទៀតកើតឡើង។ ការកំណត់បែបនេះមិនចាំបាច់ទេ។ អ្នកស្នើសុំគួរតែមានសេរីភាពក្នុងការស្នើសុំម្តងហើយម្តងទៀតដោយគ្មានការកំណត់ពេលវេលា។

**អនុសាសន៍សម្រាប់មាត្រា ១១៖**

១. ពិនិត្យ និងកែតម្រូវ មាត្រា ១១ ដោយលុបចោលនូវលក្ខខណ្ឌដែលតម្រូវឲ្យ អ្នកស្នើសុំព័ត៌មានបង្ហាញព័ត៌មានពីយែនឌ័រ (ភេទ) អាយុ សញ្ជាតិ និងមុខរបរ។

**អនុសាសន៍សម្រាប់មាត្រា ១៣៖**

១. រយៈពេលនៃការឆ្លើយតបចំពោះការស្នើសុំព័ត៌មានគួររក្សាដូចសេចក្តីព្រាងមុន គឺ៥ ថ្ងៃនៃថ្ងៃធ្វើការ។

**អនុសាសន៍សម្រាប់មាត្រា ១៥៖**

១. លុបចំណុច៤ នៃមាត្រា ១៥ ទាក់ទងនឹងដែនកំណត់ ៤០ ថ្ងៃ មុនការស្នើសុំម្តងទៀតកើតឡើង។

## ជំពូកទី ៤ មាត្រា ២០

**សេចក្តីព្រាងខែវិច្ឆិកាឆ្នាំ ២០១៩៖**

មាត្រា ២០ ចុងក្រោយបំផុតនៅតែមិនផ្លាស់ប្តូរពីកំណែមុនៗ និងបរិយាយព័ត៌មានដែលស្ថិតក្នុងករណីពិសេសអាចត្រូវបានហាមឃាត់ពីសាធារណជន (ត្រូវបានគេស្គាល់ផងដែរថាជា "ករណីលើកលែង") ។ ការលើកលែងព័ត៌មានទាំងនេះ រួមមានបញ្ហាការពារជាតិនិងសន្តិសុខជាតិ

ទំនាក់ទំនងការទូតជាមួយប្រទេសដទៃទៀត សេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ នីតិវិធីព្រហ្មទណ្ឌ និងតុលាការ ភាពឯកជនផ្ទាល់ខ្លួននិងព័ត៌មានសម្ងាត់ផ្ទៃក្នុង។ចំណុច៧ នៃមាត្រា ២០ នៃសេចក្តីព្រាងចុងក្រោយក៏រួមបញ្ចូលនូវការលើកលែងបន្ថែមមួយទៀតផងដែរៈ"ព័ត៌មានសម្ងាត់ផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិហាមឃាត់ទាំងឡាយ"

## មតិយោបល់

ចំណុចទី៧ នៃមាត្រា ២០ មានលក្ខណៈទូលំទូលាយពេកហើយខ្វះលក្ខណៈជាក់លាក់។ នេះគឺជា"បទប្បញ្ញត្តិដែលគ្របដណ្តប់លើបញ្ហាគ្រប់យ៉ាង"ដែលមិនចាំបាច់ហើយគួរតែលុបចោល។បន្ថែមលើនេះមាត្រា ២០ ចុងក្រោយបំផុតមិនមាន" ការធ្វើតេស្តសាកល្បង ៣ ផ្នែក" ដើម្បីកំណត់ថាតើព័ត៌មានលើកលែងអាចត្រូវបានហាមឃាត់ពីសាធារណជនឬអត់។ និយាមអន្តរជាតិនៃសិទ្ធិទទួលព័ត៌មានតម្រូវឲ្យមានតេស្តសាកល្បងផ្នែកទាំងបីទាក់ទងនឹងការបញ្ចេញព័ត៌មានសម្ងាត់។ របាយការណ៍របស់អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីពីសេរីភាពនៃការបញ្ចេញមតិ នៅខែឧសភាឆ្នាំ ២០១១ ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបង្ហាញពី តេស្តសាកល្បងផ្នែកទាំងបីផ្នែកដែលត្រូវតែអនុវត្តនៅពេលមានការរិតត្បិតលើសិទ្ធិសេរីភាពបញ្ចេញមតិដូចមានចែងក្នុងមាត្រា ១៩ (៣) នៃ ICCPR ។ សិទ្ធិទទួលព័ត៌មានឥឡូវនេះត្រូវបានចាត់ទុកថាជាផ្នែកមួយនៃមាត្រា ១៩ សិទ្ធិសេរីភាពនៃការបញ្ចេញមតិ[5]។

## ការធ្វើតេស្ត ៣ ផ្នែកនេះមានដូចខាងក្រោមៈ

ជំហានទី ១៖ តើការលើកលែងទាំងឡាយទាក់ទងនឹងគោលដៅឬគោលបំណងស្របច្បាប់ដែរឬទេ? ហើយបើមែន តើព័ត៌មានស្ថិតនៅក្រោមការលើកលែងណាមួយនៃការលើកលែងទាំងអស់ដែរឬទេ?

ជំហានទី ២៖ តើមានហានិភ័យពិត និងហានិភ័យដែលអាចកំណត់អត្តសញ្ញាណបានដែលធ្វើឲ្យមានគ្រោះមហន្តរាយដល់ផលប្រយោជន៍ដែលមានការការពារពីច្បាប់ដែរឬទេប្រសិនបើគេបញ្ចេញព័ត៌មាននោះ? (បង្កឲ្យមានគ្រោះមហន្តរាយធ្ងន់ធ្ងរ)

ជំហានទី ៣៖ តើគ្រោះមហន្តរាយធ្ងន់ធ្ងរនោះ ធំជាងផលប្រយោជន៍សាធារណៈក្នុងការបញ្ចេញព័ត៌មានដែរឬទេ? ប្រសិនបើផលប្រយោជន៍សាធារណៈធំជាងគ្រោះមហន្តរាយធ្ងន់ធ្ងរនោះព័ត៌មានត្រូវតែបញ្ចេញដល់សាធារណៈជន។

---

[5] A/HRC/17/27, paragraph. 69. https://www.right-docs.org/doc/a-hrc-17-27/

**អនុសាសន៍សំរាប់មាត្រា ២០៖**

១. រាប់បញ្ចូលការធ្វើតេស្ត ៣ ផ្នែកជាគោលការណ៍ទូទៅនៃមាត្រា ២០ ។ ផ្នែកដែលអាចមានដូចខាងក្រោម៖

ស្ថាប័នសាធារណៈអាចបដិសេធការផ្តល់ព័ត៌មានដល់អ្នកស្នើសុំនៅពេលដែលគ្រប់លក្ខខណ្ឌទាំងបីត្រូវបានបំពេញដូចខាងក្រោមៈ

- ព័ត៌មានដែលស្ថិតនៅក្រោមការលើកលែងមួយឬច្រើននៃករណីលើកលែងដែលបានចែងនៅក្នុងមាត្រានេះ។
- ប្រសិនបើព័ត៌មានដែលបញ្ចេញនោះ មានគ្រោះមហន្តរាយធ្ងន់ធ្ងរ និងអាចបង្កឲ្យខូចខាតដល់ផលប្រយោជន៍ដែលមានការការពារពីច្បាប់
- ការខូចខាតដល់ផលប្រយោជន៍ដែលមានការការពារពីច្បាប់នេះ ត្រូវតែធំជាងផលប្រយោជន៍សាធារណៈក្នុងការបញ្ចេញព័ត៌មាន។

២. លុបចំណុច៧ នៃមាត្រា ២០ ពីព្រោះមានលក្ខណៈទូលំទូលាយពេកនិងមិនចាំបាច់។

## ជំពូកទី ៥ មាត្រា ២៤

**សេចក្តីព្រាងខែវិច្ឆិកាឆ្នាំ ២០១៩៖**

**មាត្រា ២៤.**

គ្មានជនណាដែលផ្តល់ព័ត៌មាន ត្រូវជាប់បទព្រហ្មទណ្ឌ បទរដ្ឋប្បវេណី និងពិន័យចំពោះការរាយការណ៍ពីនរណាម្នាក់ដែលធ្វើខុសពីបទមជ្ឈិមឬបទឧក្រិដ្ឋ ដែលពួកគេបានដឹងនិង / ឬអំឡុងពេលបំពេញមុខងារ ឬកាតព្វកិច្ចរបស់ខ្លួនដែលបានធ្វើនៅចំពោះមុខអាជ្ញាធរយុត្តិធម៌ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ផ្ទុយទៅវិញពួកគេត្រូវទទួលការការពារពីការគំរាមកំហែងនិងការសងសឹក ប្រសិនបើពួកគេធ្វើដោយក្នុងគោលបំណងល្អ។ ការបរិហារកេរ្តិ៍មិនគួរត្រូវបានបំផ្លើសពីការពិតដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលនិង / ឬស្ថាប័នសាធារណៈឡើយ។

**មតិយោបល់**

មាត្រា ២៤ ដែលផ្តល់ការការពារចំពោះប្រភពព័ត៌មានមានកម្រិតពេក ។ សេចក្តីព្រាងចុងក្រោយផ្តល់ការការពារដល់អ្នកទាំងឡាយណាដែលបង្ហាញពី" បទឧក្រិដ្ឋឬបទមជ្ឈិម" ។ មាត្រា ២៤ ក៏គួរតែផ្តល់ការការពារដល់អ្នកដែលលាតត្រដាងរាល់ទម្រង់នៃការធ្វើខុសរួមទាំងអាកប្បកិរិយាមិនស្មោះត្រង់ឬសូម្បីតែការគ្រប់គ្រងមិនត្រឹមត្រូវឬកង្វះអភិបាលកិច្ចល្អទាក់ទងនឹងស្ថាប័នសាធារណៈ។

## អនុសាសន៍សម្រាប់មាត្រា ២៨

១. ពិនិត្យ និងកែតម្រូវ មាត្រា ២៨ ដើម្បីការពារប្រភពព័ត៌មានដែលបញ្ចេញឬលាតត្រដាងព័ត៌មានស្ដីពីការប្រព្រឹត្តខុស រួមមានបទព្រហ្មទណ្ឌ ការបរាជ័យក្នុងការបំពេញកាតព្វកិច្ចផ្លូវច្បាប់ អំពើពុករលួយឬភាពមិនស្មោះត្រង់ ការគ្រប់គ្រងមិនល្អឬកង្វះអភិបាលកិច្ចល្អដែលទាក់ទងនឹងស្ថាប័នសាធារណៈណាមួយ និងការគំរាមកំហែងដល់សុខភាពសាធារណៈ និងការគំរាមកំហែងដល់បរិស្ថាន ។

## ជំពូកទី ៧ មាត្រា ២៩ និង ៣០

## សេចក្ដីព្រាងខែវិច្ឆិកាឆ្នាំ ២០១៩៖

### មាត្រា ២៩.

ក្នុងករណីមានអំពើហិង្សាកើតឡើងចំពោះមន្ត្រីនៃស្ថាប័នសាធារណៈ ឬមន្ត្រីទទួលបន្ទុកព័ត៌មានដែលបំពេញភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់នេះត្រូវផ្ដន្ទាទោសដូចមានចែងក្នុងមាត្រា ៥០៦ (ការរាំងស្ទះដល់ការអនុវត្តការងារសាធារណៈ) នៃក្រមព្រហ្មទណ្ឌ។

### មាត្រា ៣០.

ជនណាដែលនិយាយបរិហារកេរ្ដិ៍ទៅស្ថាប័នសាធារណៈឬអាជ្ញាធរយុត្តិធម៌អំពីបទល្មើសណាមួយដែលបណ្ដាលឱ្យការស៊ើបអង្កេតក្លាយជាឥតប្រយោជន៍ត្រូវទទួលទណ្ឌកម្មដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ៦ (ប្រាំមួយ) ខែនិង / ឬពិន័យជាប្រាក់ពី ១០០.០០០ ( មួយរយពាន់) រៀលទៅ ១.០០០.០០០ (មួយលាន) រៀល។

## មតិយោបល់

ជំពូកពិន័យនៃច្បាប់ (ជំពូកទី ៧) មានមាត្រា ២៩ និង ៣០ គឺមិនទាក់ទងនឹងបញ្ហាតម្លាភាពរបស់រដ្ឋាភិបាល និងស្មារតីស្នូលនិងគោលបំណងនៃសិទ្ធិទទួលព័ត៌មាន។ យោងតាមអង្គការសិទ្ធិមនុស្សអន្តរជាតិនិងសេរីភាពក្នុងការបញ្ចេញមតិមាត្រា ១៩" ច្បាប់សិទ្ធិទទួលព័ត៌មាន គួរតែលើកកម្ពស់ការបើកចំហរការទទួលបានព័ត៌មានដោយអាជ្ញាធរសាធារណៈ។ ច្បាប់បែបនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឲ្យមានការរាយការណ៍ត្រឹមត្រូវ និងកម្រិតការបោះពុម្ពផ្សាយព័ត៌មានដែលអាចឈានដល់ការបរិហារកេរ្ដិ៍នៅក្នុងសង្គមប្រជាធិបតេយ្យ។"អាទិភាពនិងស្មារតីចំបងនៃច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន គួរតែមានលក្ខណៈវិជ្ជមាន។ វាគួរតែលើកទឹកចិត្តឱ្យពលរដ្ឋស្វែងរកនិងទទួលបានព័ត៌មាន និងមិនដាក់ទណ្ឌកម្មពួកគេទេ។ មាត្រាទាំងនេះអាចបំបាក់ទឹក

ចិត្តនិងបង្កើតការភ័យខ្លាចចំពោះប្រជាពលរដ្ឋ និងរារាំងពួកគេពីការស្នើសុំព័ត៌មានទៅអង្គភាព និងស្ថាប័នសាធារណៈនានា។

**អនុសាសន៍សម្រាប់មាត្រា ២៩ និង ៣០៖**

សូមលុបមាត្រា ២៩ និង ៣០។ មាត្រាទាំងនេះ មិនពាក់ព័ន្ធនឹងច្បាប់នេះឡើយ។ នៅក្នុងក្រមព្រហ្មទណ្ឌមានបទប្បញ្ញត្តិជាច្រើនហើយដែលអាចអនុវត្តក្នុងការដោះស្រាយករណីបែនេះ។

**ជំពូកទី ៩ មាត្រា ៣៧**

**មតិយោបល់**

មាត្រា ៣៧ ក្នុងសេចក្តីព្រាងច្បាប់ដំបូងបញ្ជាក់យ៉ាងច្បាស់ពីអាទិភាពនៃច្បាប់ដែលជាផ្នែកមួយនៃក្របខណ្ឌច្បាប់និងស្ថាប័នច្បាប់ដែលមានស្រាប់។

**អនុសាសន៍សម្រាប់មាត្រា ៣៧៖**

១. សូមស្រង់មាត្រា ៣៧ដែលមាននៅក្នុងសេចក្តីព្រាងមុន ត្រឡប់មកវិញ៖ "ច្បាប់នេះត្រូវមានអាទិភាលើច្បាប់ដទៃ ក្នុងករណីដែលបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតផ្ទុយនឹងការផ្តល់ឲ្យនៃច្បាប់នេះ" ។

**បណ្តឹងឧទ្ធរណ៍និងនិយាមអន្តរជាតិ**

និយាមអន្តរជាតិមួយដ៏សំខាន់ដែលទទួលយកបានទាក់ទងនឹងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន គឺទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ ។ ជំពូកទី ៦ មាត្រា ២៦ និង ២៧ ពិពណ៌នាអំពីប្រព័ន្ធទូទៅនៃបណ្តឹងឧទ្ធរណ៍សម្រាប់ការស្នើសុំព័ត៌មាន។

ទោះយ៉ាងណាក៏ដោយមិនមានបទប្បញ្ញត្តិសម្រាប់ប្រព័ន្ធបណ្តឹងឧទ្ធរណ៍រដ្ឋបាល ឬការបង្កើតស្នងការព័ត៌មានឯករាជ្យ ឬគណៈកម្មាធិការព័ត៌មានឯករាជ្យនានា ដែលនឹងពិចារណាលើបណ្តឹងឧទ្ធរណ៍និងជួយដើម្បីធានាឲ្យមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព។ ស្នងការព័ត៌មានឯករាជ្យឬគណៈកម្មាធិការព័ត៌មានឯករាជ្យនេះជាយន្តការដែលប្រទេសជាង ៨០ ដែលមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានបានទទួលយក។ ដោយសារតែកង្វះថវិកា ការបង្កើតស្ថាប័នថ្មីប្រហែលជាមិនអាចធ្វើទៅបានទេនៅពេលនេះនៅក្នុងប្រទេសកម្ពុជា។ ទោះយ៉ាងណា គេអាចអនុវត្តប្រព័ន្ធការិយាល័យប្រជាពលរដ្ឋដែលមានស្រាប់ (ដែលគេកំពុងតែបង្កើតនៅក្នុងប្រទេសកម្ពុជា) ចំពោះបណ្តឹងឧទ្ធរណ៍ យ៉ាងហោចណាស់រង់ចាំរហូតដល់ការបង្កើតស្ថាប័នស្នងការព័ត៌មាន នៅពេលអនាគត។